00702133

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 03 / 06 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

D11/1/4/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

សំណុំរឿងលេខ: **០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១)**

ភាគីដាក់ឯកសារ: អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សេង ចាន់ធារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១១

ភាសាដើម: អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ សាធារណៈ (កោសលុប)/

---

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី

---

<u>ដាក់ដោយ</u>៖

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**
សេង ចាន់ ធារី
**មេធាវីជាតិរបស់អ្នកដាក់ពាក្យ**
ជួង ជូងី
(រង់ចាំការទទួលស្គាល់គាត់ជាផ្លូវការដោយ អ.វ.ត.ក)

<u>ផ្ញើជូន</u>៖

**ចៅក្រមអង្គបុរេជំនុំជម្រះ**៖
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម Rowan DOWNING

<u>ចម្លងជូន</u>៖

**សហមេធាវីនាំមុខ**
**និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**៖
ពេជ អង្គ
Elisabeth SIMMONEAU-FORT
Lyma NGUYEN
សំ សុគង់
Emmanuel JACOMY

**សហព្រះរាជអាជ្ញា**៖
ជា លាង
Andrew CAYLEY
**សហចៅក្រមស៊ើបអង្កេត**៖
យូ ប៊ុនឡេង
Siegfried BLUNK
**អង្គភាពគាំពារជនរងគ្រោះ**៖
រោង ឈុង

00702134

D11/1/4/1

---

ហុង គីមសួន
Silke STUDZINSKY
Emmanuel JACOMY
១៧១

Christoph Sperfeldt

## I. សេចក្តីផ្តើម និង បណ្តឹងឧទ្ធរណ៍

១. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១១ នាងខ្ញុំ សេង ចាន់ធារី (ដែលចាប់ពីពេលនេះតទៅហៅថា "**ម្ចាស់បណ្តឹងឧទ្ធរណ៍**") បានដាក់ពាក្យសុំជាសាធារណៈមួយដែលមានចំណងជើងថា *"ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៣/០០៥"* ដែលមានឈ្មោះ [redacted] ជូនផ្នែកគាំពារជនរងគ្រោះ ("VSS") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**")។ ពាក្យសុំនេះក៏ត្រូវបានដាក់ជូនសហចៅក្រមស៊ើបអង្កេត ("**ស.ច.ស**") ១៩ថ្ងៃក្រោយមក គឺ នៅថ្ងៃទី ២២ ខែ មេសា ដូចដែលបានបញ្ជាក់អះអាងដោយផ្ទាល់មាត់ចំពោះកញ្ញា នៅពេលល្ងាចថ្ងៃដដែលនោះ ដោយលោក រាជ សម្បត្តិ (ដែលទើបទទួលមរណៈភាពថ្មីៗ) ដែលនៅពេលនោះលោកជាប្រធានផ្នែកកិច្ចការសាធារណៈ អ.វ.ត.ក ក្នុងឱកាសពួកគាត់អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីទទួលការហៅទូរស័ព្ទចូលរបស់វិទ្យុអាស៊ីសេរី។ រហូតមកទល់នឹងពេលនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនដែលបានទទួលឯកសារផ្លូវការបញ្ជាក់ពីការទទួលពាក្យសុំទាក់ទងនឹង [redacted] របស់ខ្លួនឡើយ។

២. នៅពេលរសៀលថ្ងៃសុក្រ ទី ២៩ ខែ មេសា ឆ្នាំ ២០១១ ស.ច.ស បានធ្វើការប្រកាសជាសាធារណៈ អំពីការបិទកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ដោយសម្តីតែមួយប្រយោគប៉ុណ្ណោះ។

៣. នៅពេលរសៀលថ្ងៃអង្គារ ទី ៣ ខែ ឧសភា ឆ្នាំ ២០១១ បន្ទាប់ពីចុងសប្តាហ៍ដែលមានថ្ងៃឈប់សម្រាករយៈពេលច្រើនថ្ងៃរួចមក មេធាវីជាតិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ លោក ជួង ជូងី[១]

---

[១] សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែ អ.វ.ត.ក មិនទាន់បានឆ្លើយតបទៅនឹងលិខិតផ្ទេរសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ជូនមេធាវី ជួង ជូងី ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ដែលបានដាក់ជាមួយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១១ នៅឡើយ។ ប្រសិនបើនៅក្នុងស្ថានភាពនេះ និងដោយគិតដល់វិធាន ២៣ ស្ទួនពីរ (១) ម្ចាស់បណ្តឹងឧទ្ធរណ៍គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង ដែលរង់ចាំការទទួលស្គាល់លោក ជួង ជូងី របស់ អ.វ.ត.ក ពេលនោះ គាត់ផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨ ដែលមានចំណងជើងថា "សេចក្តីណែនាំអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាងក្នុងការបង្ហាញជូនអង្គបុរេជំនុំជម្រះផ្ទាល់" ដែលលើកឡើងថា "(១) ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាងស្របច្បាប់អាចត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកដើម្បីបង្ហាញជូនអង្គបុរេជំនុំជម្រះផ្ទាល់ នៅពេលផលប្រយោជន៍របស់ខ្លួនខុសប្លែកពីផលប្រយោជន៍របស់ព្រះរាជអាជ្ញា"។ វិធាន ២៣ ស្ទួនពីរ (១) នៃវិធានផ្ទៃក្នុង ចែងថា "ចាប់ពីពេលចេញដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បានចុះហត្ថលេខា ដើម្បីទទួលឯកសារពីរផ្សេងគ្នា (ដែលចុះកាលបរិច្ឆេទ ដូចគ្នាទៅនឹងកាលបរិច្ឆេទនៃការប្រកាសបិទកិច្ចស៊ើបសួរ) ដោយមានសេចក្តីសម្រេចរបស់ ស.ច.ស ដែលមានចំណងជើងថា "ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី" ដោយបានបដិសេធពាក្យសុំទាក់ទងនឹង [redacted] របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនៅក្នុងសំណុំរឿង ០០៣ និងនៅក្នុងសំណុំរឿង ០០៤ ("ដីកាសម្រេចបដិសេធ")។ ឯកសារទាំងពីរមានខ្លឹមសារដូចគ្នាបេះបិទ លើកលែងតែការចុះលេខសំណុំរឿង ហើយឯកសារទាំងពីរត្រូវបានចាត់ចំណាត់ថ្នាក់ថាជាប្រភេទឯកសារ "សម្ងាត់" ទោះបីជាឈ្មោះរបស់ជនត្រូវចោទទាំងប្រាំនាក់ និងវិសាលភាពនៃកិច្ចស៊ើបសួរ មិនត្រូវបានលើកឡើងក៏ដោយ។

៤. នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១ ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្សព្វផ្សាយសេចក្តីប្រកាសព័ត៌មានមួយ ដែលនិយាយពីចេតនារបស់គាត់ក្នុងការប្តឹងឧទ្ធរណ៍លើដីកាសម្រេចបដិសេធទាំងនេះ និងដោយមានព័ត៌មានថ្មី ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏មានបំណងដាក់ពាក្យសុំមួយទៀតប្រឆាំងនឹង [redacted] នៅក្នុងសំណុំរឿង ០០៤។

៥. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ដែលកំណត់អំពីទីកន្លែងប្រព្រឹត្តបទល្មើស និង រឿងរ៉ាវថ្មីៗនៃរឿងក្តីព្រហ្មទណ្ឌ ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣។

៦. ម្ចាស់បណ្តឹងឧទ្ធរណ៍បានដឹងហើយថា ខ្លួនមានពេលវេលា ១០ថ្ងៃ ដើម្បីធ្វើការប្តឹងឧទ្ធរណ៍ បន្ទាប់ពីថ្ងៃដែលបានទទួលដីកាសម្រេចបដិសេធ។ ដោយគិតដល់ថ្ងៃឈប់សម្រាកផ្លូវការ និងថ្ងៃសម្រាកចុងសប្តាហ៍ទាំងអស់ ម្ចាស់បណ្តឹងឧទ្ធរណ៍មានពេលវេលារហូតដល់ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ វេលាម៉ោង ៤ រសៀល ដើម្បីដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ ក្នុងនាមគាត់ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង ស្ថិតក្នុងរយៈពេលរង់ចាំការទទួលស្គាល់ពី អ.វ.ត.ក ចំពោះមេធាវីតែម្នាក់គត់របស់ខ្លួនដែលជាមេធាវីជាតិខ្មែរ លោក ជួង ជូងី ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទទួលបានព័ត៌មានស្តីពីសំណុំរឿង និងឯកសារពាក់ព័ន្ធផ្សេងទៀតរបស់តុលាការ

---

ដំណោះស្រាយតទៅ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយត្រូវតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប នៅគ្រប់ពេលទាំងអស់"។

ឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេស នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ជូនអង្គបុរេជំនុំជម្រះ ("**អ.ប.ជ**") និងដាក់ជូនអង្គភាពបកប្រែភាសារបស់ អ.វ.ត.ក ("**ITU**") និង VSS ដោយ ស្នើសុំឱ្យបកប្រែទៅជាភាសាខ្មែរ។

៧. ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យ អ.ប.ជ បដិសេធដីការបស់ ស.ច.ស ដែលបានប្រកាសថា ពាក្យសុំទាក់ទងនឹង [redacted] របស់ខ្លួន មិនអាចទទួលយកបាន ដោយហេតុថា (១) ម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រូវបានផ្តល់ឱ្យនូវគោលការណ៍ជាមូលដ្ឋាន នៃភាពយុត្តិធម៌ផ្នែកនីតិវិធីនៃការទទួលបានព័ត៌មានទាន់ពេលវេលា និងគ្រប់គ្រាន់ ស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ (២) ស.ច.ស ខកខានមិនបានដឹកនាំកិច្ចស៊ើបសួរដល់ទីកន្លែងប្រព្រឹត្តបទល្មើស និងរឿងរ៉ាវថ្មីៗនៃរឿងក្តីព្រហ្មទណ្ឌនៃសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ជាពិសេស ទីកន្លែងដែលពាក់ព័ន្ធនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ពោលគឺ ទីក្រុងភ្នំពេញ និង ភូមិភាគបូព៌ា និងប្រការដែលពាក់ព័ន្ធផងដែរគឺថា ស.ច.ស ខកខានមិនបានរក្សាឯករាជ្យភាពតុលាការ (៣) ស.ច.ស អនុវត្តខុស និងបកស្រាយខុសអង្គហេតុ និងអង្គច្បាប់ ដូចជា គោលការណ៍ "សហឧក្រិដ្ឋកម្មរួម" និង គោលការណ៍ "ផែនការ និងគោលបំណងរួម" ជាដើម និង (៤) ស.ច.ស ខកខានមិនបានផ្តល់សេចក្តីសម្រេចដែលមានបញ្ជាក់ហេតុផល នៅពេលដែលខ្លួនសម្រេចមិនទទួលយកបានពាក្យសុំទាក់ទងនឹង [redacted] របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី។

៨. ម្ចាស់បណ្តឹងឧទ្ធរណ៍កំពុងធ្វើឱ្យបណ្តឹងឧទ្ធរណ៍នេះក្លាយជាឯកសារសាធារណៈ ពីព្រោះគាត់កំពុងធ្វើការឆ្លើយតបទៅនឹងខ្លឹមសារដែល (១) ថា ស្ថិតនៅក្នុងផ្នែកសាធារណៈរួចហើយ និងមិនបង្កការខូចខាត ឬទាក់ទងទៅនឹងកិច្ចស៊ើបសួរនោះទេ និង(២) ថា **មានផលប្រយោជន៍សាធារណៈច្រើន** ជាពិសេស ពីព្រោះវាពាក់ព័ន្ធទៅនឹងគុណភាពនៃកិច្ចការរដ្ឋបាលរបស់តុលាការ និង កិច្ចការផ្សះផ្សាជាតិ និងការកសាងកេរដំណែលកាន់តែវិជ្ជមានឡើងសម្រាប់អ្នកជំនាន់ក្រោយនាពេលអនាគត។

## II. **សេចក្តីសង្ខេបអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធ**

### **ក. អង្គហេតុ**

៩. នៅក្នុងពាក្យសុំទាក់ទងនឹង [redacted] ម្ចាស់បណ្តឹងឧទ្ធរណ៍បានហៅឈ្មោះជាសាធារណៈ និងបានលើកឡើងយ៉ាងច្បាស់លាស់អំពី [redacted]

[redacted] ឱ្យទទួលខុសត្រូវដោយផ្ទាល់ ជាលក្ខណៈបុគ្គល ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (រួមទាំងធាតុផ្សំផ្លូវច្បាប់នៃការសម្លាប់មនុស្ស ការនិរទេស ការដាក់ជាទាសករ ការឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើបាបផ្នែកនយោបាយ) នៅក្នុងតួនាទីរបស់ពួកគេក្នុងនាមជា [redacted] និងចំពោះការរួមចំណែកផ្នែកសម្ភារៈនៅក្នុងការបង្កើត និងការអនុវត្តផែនការ និងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែលបានប៉ះពាល់ដល់ប្រទេសកម្ពុជាទាំងមូល។

១០. [redacted] បានកាន់កាប់តួនាទីជាន់ខ្ពស់ នៅក្នុងឋានានុក្រមរបបកម្ពុជាប្រជាធិបតេយ្យ ដែលតាមរយៈតួនាទីទាំងនេះ ពួកគេអាចជះឥទ្ធិពលលើការបង្កើត និងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា (“CPK”) ដោយផ្ទាល់ និងករណីភាគច្រើន ធ្វើឡើងតាមរយៈអ្នកនៅក្រោមបង្គាប់ពួកគេ ។

១១. យោងតាមដីកាដំណោះស្រាយសំណុំរឿង ០០២ របស់ អ.វ.ត.ក *“កងទ័ពបដិវត្តន៍កម្ពុជា” (“ក.ប.ក”) គឺជាស្ថាប័នសំខាន់របស់កម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយ CPK ពឹងផ្អែកជាសំខាន់ទៅលើកងកម្លាំង ដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់ខ្លួន ដោយធ្វើឱ្យកងទ័ពក្លាយជាផ្នែកមួយសំខាន់នៃឧបករណ៍រដ្ឋាភិបាលរបស់ខ្លួន”* (កថាខណ្ឌ ១១៣)។ ក្នុងឋានៈជាអ្នកទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុងកងទ័ព ក.ប.ក បានអនុវត្តការបោសសម្អាតតាមបញ្ជារបស់មជ្ឈិមបក្ស (កថាខណ្ឌ ១៤៦)។ *“គណៈកម្មាធិការយោធាដើរតួនាទីជាអង្គការមជ្ឈិមបក្ស ហើយដូច្នេះ គណៈកម្មាធិការយោធាធានាលើការគ្រប់គ្រង កងទ័ពបដិវត្តន៍កម្ពុជាតាមរយៈមជ្ឈិម។ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធា ជួនកាលប្រជុំរួមគ្នា ដើម្បីសម្រេចលើបញ្ហាយោធានានា* ***ដែលត្រូវអនុវត្តបទបញ្ជាយុទ្ធសាស្ត្រ ជារួមទៅលើកងកម្លាំងប្រដាប់អាវុធ****”* (កថាខណ្ឌ ១២០)។ (សេចក្តីបញ្ជាក់បន្ថែម)។

១២. ម្តងទៀត យោងតាមដីកាដំណោះស្រាយសំណុំរឿង ០០២ RAK *“បានបង្កើតនូវបញ្ជាការដ្ឋានពីរ ដែលបញ្ជាការដ្ឋានទីមួយៗត្រួតពិនិត្យ ដោយផ្ទាល់លើប្រតិបត្តិការទាហានរបស់កងពលជាច្រើន។* ***បញ្ជាការដ្ឋានទាំងពីរនេះត្រូវបានបង្កើតឡើងនៅភូមិភាគបូព៌ា។*** *បញ្ជាការដ្ឋានទីមួយមានទីតាំងនៅតាមផ្លូវជាតិលេខ១ ក្នុងតំបន់២៣... បញ្ជាការដ្ឋានទីពីរ មាន ទីតាំងនៅតាមបណ្តោយផ្លូវជាតិ*

*លេខ៧ ហើយស្ថិតនៅក្នុងភូមិភាគបូព៌ាផងដែរ។ បញ្ជាការដ្ឋាននេះ រួមមាន... កងពល ១៧៥ រួមបញ្ចូលសមាសភាពមកពីកងពល ៥០២*" (កថាខណ្ឌ ១៣០) [redacted]។

១៣. ម្ចាស់បណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ជាបញ្ហាច្បាប់អន្តរជាតិ [redacted] ត្រូវទទួលខុសត្រូវរួមគ្នាផ្ទាល់លើឭសនកម្មផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេលដួលរលំ និងការចាកចេញទាំងហ្វូងពីទីក្រុងភ្នំពេញ (**ការផ្លាស់ទីលំនៅ ដំណាក់កាលទី** I) នៅពេលឪពុករបស់គាត់ ដែលជាមេបញ្ជាការយោធា លន់ នល់ "បានបាត់ខ្លួន" នៅក្នុងចំណោមឭសនកម្មផ្លូវច្បាប់នានាផ្សេងទៀត និងការផ្លាស់ទីលំនៅប្រជាជនភូមិភាគបូព៌ា (**ការផ្លាស់ទីលំនៅដំណាក់កាលទី** III) នៅពេលខ្មែរក្រហមបានឃុំឃាំងគាត់ និងក្រុមគ្រួសាររបស់គាត់ដំបូងនៅវត្តផ្លូក **និងបន្ទាប់មកនៅមន្ទីរសន្តិសុខបឹងរ៉ៃ** (Boeung Rai) ដែលជាកន្លែងដែលគាត់មានពិសោធន៍ និងបានឃើញការស្លាប់ម្តាយរបស់ខ្លួនក្នុងចំណោមប្រជាជន ៣០.០០០ (បីម៉ឺន) នាក់ ដែលត្រូវបានសន្មតថាត្រូវបានសម្លាប់ចោល នៅបឹងរ៉ៃ។

១៤. **សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោក Andrew Cayley** សហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ហៅឈ្មោះ "ភ្នំពេញ" ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស២១ និង ស២២ "ការបោសសម្អាតភូមិភាគបូព៌ា" និង "ការចូលលុកលុយ ទៅក្នុងប្រទេសវៀតណាម" ថាជាទីកន្លែងប្រព្រឹត្តបទល្មើស និងរឿងរ៉ាវព្រហ្មទណ្ឌថ្មីៗមួយចំនួន ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរសំណុំរឿង ០០៣ ដែលទីតាំងទាំងអស់នេះសុទ្ធតែមានទំនាក់ទំនងដោយផ្ទាល់រវាងម្ចាស់បណ្តឹងឧទ្ធរណ៍ និងជនត្រូវចោទ។

## ខ. ដីកាសម្រេចបដិសេធ

១៥. ស.ច.ស បានបដិសេធពាក្យសុំទាក់ទងនឹង [redacted] របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយលើកឡើងថា "*ពុំមានស្ថានភាពណាមួយក្នុងចំណោមស្ថានភាពអង្គហេតុដែលបានរៀបរាប់ខាងលើមានការពាក់ព័ន្ធទៅនឹងអង្គហេតុសត្យានុម័ត ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ឬទីបី ឡើយ ហើយក៏មិនពាក់ព័ន្ធទៅនឹងកាលៈទេសៈនានាដែលគ្របដណ្តប់លើអង្គហេតុសត្យានុម័តទាំងអស់នេះ ឬទំនងជាជួយដល់ការសម្រេចអំពីផលប៉ះពាល់ផ្នែកយុត្តាធិការ និងទម្រង់នៃការទទួលខុសត្រូវរបស់អ្នកដែលអាចជាជនសង្ស័យទាំងអស់នោះទេ*"។

00702140



១៦. ស.ច.ស បានបញ្ជាក់ហេតុផលថែមទៀតនៅក្នុងការបដិសេធរបស់ខ្លួនថា ការទាមទាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍អំពីព្យសនកម្មដែលខ្លួនបានទទួលរងដែលជាផលវិបាកផ្ទាល់នៃបទល្មើស ដែលបានចោទប្រកាន់ដែលបានប្រព្រឹត្តដោយ[redacted] *"គ្មានមូលដ្ឋាន ពីព្រោះឈ្មោះរបស់ជនជាប់សង្ស័យនៅក្នុងសំណុំរឿង ០០៣ [និងសំណុំរឿង ០០៤] គឺសម្ងាត់ ហេតុដូច្នេះហើយឈ្មោះដែលបានរៀបរាប់នៅក្នុងពាក្យសុំគ្រាន់តែជាការស្មានតែប៉ុណ្ណោះ"*។

១៧. ស.ច.ស បានសន្និដ្ឋានថា *"ហេតុដូច្នេះហើយ នៅពេលដែលព្យសនកម្មរបស់អ្នកដាក់ពាក្យសុំមិនទាក់ទងទៅនឹងអង្គហេតុណាមួយក្នុងចំណោមអង្គហេតុនានា ដែលស្ថិតក្រោមកិច្ចស៊ើបសួរ ដោយហេតុនោះ សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធពាក្យសុំ"*។

## គ. គោលការណ៍ និងច្បាប់

១៨. ច្បាប់ និងវិធានផ្ទៃក្នុងពាក់ព័ន្ធ ដែលបណ្តឹងឧទ្ធរណ៍បានយកធ្វើជាសំអាង គឺវិធានផ្ទៃក្នុង ១៤, ២១, ២៣, ២៣ ស្ទួន, ២៣ ស្ទួនបួន, ៥៣, ៥៥ និង ៧៧ស្ទួន (វិសោធនកម្មលើកទី៧) មាត្រា ១០ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ (**"ច្បាប់ អ.វ.ត.ក"**)[២] មាត្រា ៥(២) និង ៥(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (**"កិច្ចព្រមព្រៀង"**)[៣] សេចក្តីប្រកាសអំពីគោលការណ៍គ្រឹះនៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយសារបទឧក្រិដ្ឋ និងការរំលោភអំណាច (**"គោលការណ៍គ្រឹះ"**)[៤] មាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (**"ICCPR"**) និងមាត្រា ៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ (**"សេចក្តីណែនាំអនុវត្ត"**)[៥]។

---

[២] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦)។

[៣] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

[៤] សេចក្តីប្រកាសគោលការណ៍គ្រឹះនៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទឧក្រិដ្ឋ និងការរំលោភអំណាច ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចមហាសន្និបាត ៤០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥។

[៥] ត្រូវបានអនុម័ត និងបើកចំហសម្រាប់ចុះហត្ថលេខា ធ្វើសច្ចាប័ន និងចូលជាសមាជិកដោយសេចក្តីសម្រេចមហាសន្និបាត ២២០០ក (XXI) ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ យោងតាមមាត្រា ៤៩ នៅ http://www2.ohchr.org/english/law/ccpr.htm.

១៩. កាន់តែពិសេសទៀតនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍គូសបញ្ជាក់ថា:

(i) គោលការណ៍ជាមូលដ្ឋានរបស់វិធាន ២១ ១(គ) នៃវិធានផ្ទៃក្នុង ចែងថា:

"*អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី*"។

(ii) បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមវិធាន ២៣ស្ទួន នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តសម្រាប់ការចូលរួមរបស់ជនរងគ្រោះ (សេចក្តីបន្ថែម ក: ទម្រង់បែបបទព័ត៌មានជនរងគ្រោះ) ចែងថា:

"*ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ... បង្ហាញផលប៉ះពាល់ដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត...*" (សេចក្តីបញ្ជាក់បន្ថែម)។

(iii) វិធាន ៥៥(១) បទប្បញ្ញត្តិទូទៅទាក់ទងនឹងការស៊ើបសួរ ចែងថា:

"*ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ*"។ (សេចក្តីបញ្ជាក់បន្ថែម)។

(iv) វិធាន ៥៦(១) និង (២) ព័ត៌មានសាធារណៈធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ចែងថា:

"*ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ... ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាច... ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី។ និង... ក្នុងកាលៈទេសៈពិសេស ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬ អ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ...*"
សេចក្តីបញ្ជាក់បន្ថែម)។

២០. សេចក្តីបន្ថែម (ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល) នៅក្នុងសៀវភៅ *របបួនទាំងប្រាំពីរនាក់សម្រាប់ការចោទប្រកាន់: ការទទួលខុសត្រូវលើបទឧក្រិដ្ឋរបស់ខ្មែរក្រហម* និពន្ធដោយលោកសាស្ត្រាចារ្យ Stephen Heder និងដោយមេធាវីអន្តរជាតិ លោក Brian D. Tittemore និងអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវច្បាប់ (Michigan Law Review) ដែលមានចំណងជើងថា Liberal Legal Norms Meet Collective Criminality និពន្ធដោយសាស្ត្រាចារ្យ John D. Ciorciari បានសង្ខេបយ៉ាងសាមញ្ញ អំពីរឿងរ៉ាវផ្លូវច្បាប់ អន្តរជាតិពីមុនដែលបង្ហាញពីការទទួលខុសត្រូវជាលក្ខណៈបុគ្គល ដែលលើកឡើងថា និយាយឱ្យចំបំផុត គឺនៅពេលដែលជនល្មើសពិតជាបានប្រព្រឹត្តជាក់ស្តែងនូវអំពើឧក្រិដ្ឋដែលបានលើកឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវជាលក្ខណៈបុគ្គលក៏អាចត្រូវបានបង្ហាញផងដែរតាមរយៈ ទម្រង់បែបបទនៃការចូលរួមឧក្រិដ្ឋកម្មផ្សេងទៀត ដូចជាការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ការចូលរួមនៅក្នុងផែនការរួម និងគោលបំណងរួម ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ (សហឧក្រិដ្ឋកម្មរួម) ឬមិនអើពើចំពោះការជួយ និងជំរុញបទឧក្រិដ្ឋ។

**ឃ. ទឡ្ហីករណ៍**

***ទឡ្ហីករណ៍ទីមួយ៖***

***ស.ច.ស បានរំលោភលើវិធាន ៥៦ វិធាន ២១ នៃវិធានផ្ទៃក្នុង គោលការណ៍គ្រឹះនៃសិទ្ធិជនរងគ្រោះ និងគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌ផ្នែកនីតិវិធីក្នុងការផ្តល់ព័ត៌មានជាសាធារណៈ ស្តីពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤***

២១. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានទទួលប្រយោជន៍ពីគោលការណ៍ជាមូលដ្ឋាន នៃភាពយុត្តិធម៌ផ្នែកនីតិវិធី ដោយការទទួលបានព័ត៌មានទាន់ពេលវេលា និងគ្រប់គ្រាន់ស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នោះទេ។

២២. នៅក្នុងអំឡុងពេល ១ឆ្នាំកន្លះ ចាប់តាំងពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបី ដែលបង្កើតជាសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ស.ច.ស បានបិទបាំងម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយខកខានមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរ ដើម្បីឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ និងជនរងគ្រោះដែលមានចំណាប់អារម្មណ៍ផ្សេងទៀតអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមែនកើតឡើង

ដោយសារព័ត៌មានដែលបានមកពី ស.ច.ស នោះទេ ប៉ុន្តែដោយសារការស្រាវជ្រាវផ្ទាល់ខ្លួនរបស់គាត់។

២៣. ភាពយុត្តិធម៌ផ្នែកនីតិវិធីរួមបញ្ចូលទាំងព័ត៌មានទាន់ពេលវេលា សមភាព និងនីតិវិធីប្រកបដោយតម្លាភាព និងច្បាស់លាស់ នៅពេលដែលសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ត្រូវបានផ្តល់ឱ្យត្រូវបានគូសបញ្ជាក់ និងត្រូវបានពន្យល់ត្រឹមត្រូវ។ ភាពយុត្តិធម៌ផ្នែកនីតិវិធីនាំឱ្យមានក្តីសង្ឃឹមថាបញ្ហានឹងត្រូវបានដោះស្រាយត្រឹមត្រូវ ច្បាស់លាស់ និងអាចស្មានទុកជាមុនបាន។ ផ្ទុយទៅវិញម្ចាស់បណ្តឹងឧទ្ធរណ៍ បានជួបប្រទះនឹងស្ថានភាពដែលផ្ទុយនឹងគោលការណ៍ទាំងអស់នេះ ដោយសារតែការរក្សាការសម្ងាត់ ការគំរាមកំហែង និងការយឺតយ៉ាវដែលមិនសមហេតុផល នៅពេលម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

២៤. ស្របតាមវិធាន ៥៦(ក) នៃវិធានផ្ទៃក្នុង ស.ច.ស អាច *"តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬ ដើម្បីកែតម្រូវព័ត៌មានមិនពិត ឬ ព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំ"* និងស្របតាមវិធាន ៥៦(ខ) នៃវិធានផ្ទៃក្នុង *"ក្នុងកាលៈទេសៈពិសេស ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬ អ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ"*។

២៥. អ.វ.ត.ក បានយល់ឃើញថា មានផលប្រយោជន៍សាធារណៈច្រើននៅក្នុងសំណុំរឿងនានាដែល អ.វ.ត.ក ធ្វើការស៊ើបអង្កេត និងចោទប្រកាន់ រួមទាំងសំណុំរឿង ០០៣ និង ០០៤ ផងដែរ។ ទោះបីជាកិច្ចស៊ើបសួរមានលក្ខណៈសម្ងាត់ខ្លាំងក៏ដោយ ក៏យ៉ាងហោចណាស់ត្រូវតែមានកិច្ចប្រឹងប្រែងធ្វើការជូនដំណឹង និងណែនាំជនរងគ្រោះ ពាក់ព័ន្ធនឹងអ្វីដែលពួកគេត្រូវសង្ឃឹមទុកនៅក្នុងសំណុំរឿងទាំងអស់នេះ ដូចដែលបានកើតឡើងនៅក្នុងសំណុំរឿង ០០២ នៅពេលដែល ស.ច.ស បានធ្វើការប្រកាសជាសាធារណៈ អំពីវិសាលភាពនៃកិច្ចស៊ើបសួរ មុនពេលធ្វើការសន្និដ្ឋានលើកិច្ចស៊ើបសួរទាំងអស់នោះ[៦] ចំណែកឯសេចក្តីសង្ខេបលម្អិតនៃកិច្ចស៊ើបសួរត្រូវបានធ្វើឡើងជាសាធារណៈ

---

[៦] ក.ស.ច.ស "សេចក្តីប្រកាសព័ត៌មាន" ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅ http://www.eccc.gov.kh/ english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf. នៅក្នុង សំណុំរឿង ០០២ ក.ស.ច.ស បានផ្តល់សេចក្តីប្រកាសព័ត៌មានយឺតយ៉ាវតែមានប្រយោជន៍ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដោយជូនដំណឹងដល់ សាធារណជនអំពីអំពើផ្សេងៗប្រឆាំងនឹងក្រុមប្រជាជន និងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋ ក្រោម "វិសាលភាពនៃកិច្ចស៊ើបសួរ" និងលើកឡើងថា "ប្រសិនបើជនរងគ្រោះ

រីឯជនរងគ្រោះត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ[៦]។ សេចក្តីប្រកាសព័ត៌មានរបស់ ស.ច.ស ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទោះបីជាធ្វើឡើងយឺតយ៉ាវក៏ដោយ បានផ្តល់គោលការណ៍ណែនាំជាសាធារណៈដំបូង ដែលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ជនរងគ្រោះ ត្រូវបានពន្យារពេលកំណត់ថែមទៀត ដើម្បីឱ្យអ្នកដាក់ពាក្យសុំអាចដាក់ជូនព័ត៌មានបន្ថែមដែលគាំទ្រការទាមទាររបស់ខ្លួន បន្ទាប់ពីមានសេចក្តីប្រកាសព័ត៌មាន។

២៦. នៅខែមករា ឆ្នាំ ២០១០ នៅពេលដែលចៅក្រម អ.វ.ត.ក បានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួននៅក្នុងសំណុំរឿង ០០២ ជនរងគ្រោះនៃរបបខ្មែរក្រហម ជាង ២.០០០នាក់ បានដាក់ពាក្យចូលរួមក្នុងការជំនុំជម្រះក្តី និងស្នើសុំសំណង។ ទាំងនៅក្នុងសំណុំរឿង ០០៣ ទាំងនៅក្នុងសំណុំរឿង ០០៤ អ្នកដែលអាចជាជនរងគ្រោះ ដែលត្រូវបានគេប៉ាន់ស្មានថាមានចំនួនលើសពី ១០០.០០០ នាក់[៨] ត្រូវបានរាំងជាលក្ខណៈប្រព័ន្ធមិនឱ្យចូលរួមក្នុងការជំនុំជម្រះក្តីទេ ពីព្រោះពុំមានការផ្តល់ព័ត៌មានអំពីឈ្មោះជនជាប់សង្ស័យ អំពីឧក្រិដ្ឋកម្ម និងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋដែល ស.ច.ស បានទទួលឡើយ។ ក្រោយពេលបិទកិច្ចស៊ើបសួរដែលធ្វើឡើងអស់រយៈពេល ២០ខែ នៅក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នៅពេលដែលកិច្ចស៊ើបសួរ ត្រូវបានប្រកាសបិទ ចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនតែបួននាក់ប៉ុណ្ណោះ។

២៧. ចម្លើយនានានៅក្នុងផ្នែក "សំណួរសម្លើយ ("FAQ") ស្តីពីសំណុំរឿង ០០៣" ត្រូវបានដាក់នៅលើគេហទំព័រ អ.វ.ត.ក កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១[៩]។ ចំណុចនេះ ធ្វើឡើងក្រោយសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ព នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ នៅពេលព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងដល់សាធារណជន អំពីវិសាលភាពនៃកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០៣ និង

---

ចង់ក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មដែលបានលើកឡើង ត្រូវតែផ្ទាល់ខ្លួន និងទាក់ទងផ្ទាល់ទៅនឹងស្ថានភាពអង្គហេតុមួយ ឬច្រើន ដែលបង្កើតជាមូលដ្ឋាននៃកិច្ចស៊ើបសួរដែលកំពុងធ្វើ"។

[៧] សូមមើល ព័ត៌មានសាធារណៈរបស់សហចៅក្រមស៊ើបអង្កេត នៅ http://www.eccc.gov.kh/en/articles/ conclusion-judicial-investigation-case-002 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០។

[៨] ការបិទសំណុំរឿងអាចឆ្លុះបញ្ចាំងពីការយល់ឃើញជាផ្លូវការពី "ខ្មែរក្រហម" កាសែត *The Cambodia Daily* ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រមុខ សរសេរដោយ Douglas Gillison។

[៩] "សំណួរដែលត្រូវបានសួរញឹកញាប់ស្តីពីសំណុំរឿង ០០៣" នៅ http://www.eccc.gov.kh/en/articles/frequently-asked-questions អំពីសំណុំរឿង ០០៣។

ពេលកំណត់សម្រាប់អ្នកដែលអាចជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើការដាក់ពាក្យ។
បន្ទាប់ពីពិចារណាឃើញថា សំណួរចម្លើយ ត្រូវបានដាក់នៅលើ អ៊ីនធឺណិត បន្ទាប់ពីមានសេចក្តីប្រកាសព័ត៌មានរបស់ការិយាល័យសហព្រះរាជអាជ្ញា និងអង្គហេតុដែល ស.ច.ស បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរដំបូងរួចហើយ
ការចេញព័ត៌មាននេះអាចត្រូវបានបកស្រាយថា ជាការបំបាក់ទឹកចិត្តជាផ្លូវការ ចំពោះជនរងគ្រោះក្នុងការដាក់ពាក្យ។

២៨. កម្រិតនៃការគោរពដែលបានផ្តល់ឱ្យជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម នៅក្នុងសំណុំរឿង ០០៣ មិនស្មើនឹងកម្រិតនៃការគោរពដល់ជនរងគ្រោះក្នុងសំណុំរឿង ០០២ ទេ ដោយសារតែកង្វះការផ្សព្វផ្សាយការជូនដំណឹងដល់ជនរងគ្រោះអំពីព័ត៌មានស្តីពីសំណុំរឿង ០០៣។ ក្រៅពីសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការដឹកនាំកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានបង្ហាញឱ្យដឹងថា ការគោរពសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះមិនមែនជាអាទិភាពរបស់តុលាការទេ នៅពេលដែលជនរងគ្រោះត្រូវបានបដិសេធឱកាសដាក់ពាក្យក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងមានប្រសិទ្ធភាព ដោយហេតុថា ពេលកំណត់សម្រាប់ការដាក់ពាក្យ គឺថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ យោងតាមវិធាន ២៣ ស្ទួន (២) នៃវិធានផ្ទៃក្នុង ដោយពុំអនុញ្ញាតឱ្យមានការពន្យារពេលឡើយ។

២៩. សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ស្របតាមឆន្ទានុសិទ្ធិដែលបានចែងនៅក្នុងវិធាន ៥៤ នៃវិធានផ្ទៃក្នុង មិនបានធ្វើឱ្យ ស.ច.ស រួចផុតពីការទទួលខុសត្រូវក្នុងការជូនដំណឹងដល់សាធារណជន ជនរងគ្រោះ និងអ្នកដែលអាចជាដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានត្រឹមត្រូវ អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ និងអំពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នោះទេ។

៣០. ស.ច.ស មិនគ្រាន់តែខកខាននៅក្នុងកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងដល់សាធារណជន ស្របតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ស.ច.ស ថែមទាំងបានធ្វើទុក្ខបុកម្នេញ សហព្រះរាជអាជ្ញាអន្តរជាតិចំពោះការបំពេញតួនាទីរបស់គាត់ថែមទៀត នៅក្នុង "*ការផ្តល់ឱ្យសាធារណជននូវសេចក្តីសង្ខេបពិតនៃព័ត៌មានដែលមាននៅក្នុងសេចក្តីសន្និដ្ឋាន[បញ្ជូនរឿងឱ្យស៊ើបសួរ] ដោយធ្វើការពិចារណាអំពីសិទ្ធិនៃការការពារខ្លួន និងផលប្រយោជន៍របស់ជនរងគ្រោះ សាក្សី និងបុគ្គល*

*ផ្សេងទៀត ដែលបានលើកឡើងនៅក្នុងនោះ ព្រមទាំងលក្ខខណ្ឌ កំណត់នៃកិច្ចស៊ើបសួរ* យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង ដោយធ្វើការចោទប្រកាន់រូបគាត់ពី *"ការមិនគោរពតុលាការ"* [១០]។

៣១. មកទល់ពេលនេះ ស.ច.ស នៅតែខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងដល់សាធារណជន ស្របតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុង។

៣២. នេះជាការបំពានលើគោលការណ៍គ្រឹះ ដែលចែងថា *"ជនរងគ្រោះត្រូវទទួលបានការប្រព្រឹត្តដោយសេចក្តីមេត្តា និងគោរពដល់សេចក្តីថ្លៃថ្នូររបស់ពួកគាត់។ ពួកគាត់មានសិទ្ធិក្នុងការទទួលបានយន្តការនៃយុត្តិធម៌ និងទទួលបានសំណងភ្លាមរហ័ស ដូចមានចែងដោយបទប្បញ្ញត្តិច្បាប់ជាតិសម្រាប់ព្យសនកម្មដែលពួកគាត់បានទទួលរង"*[១១] និង *"ជនរងគ្រោះត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិក្នុងការស្នើសុំសំណងតាមរយៈយន្តការបែបនេះ"*[១២]។ ជាពិសេស គោលការណ៍ទី៦ ចែងថា: *ភាពទទួលខុសត្រូវនៃដំណើរការតុលាការ និងរដ្ឋបាល ចំពោះសេចក្តីត្រូវការរបស់ជនរងគ្រោះគួរតែមានការជួយសម្រួលតាមរយៈ៖*

*ក. ការជូនដំណឹងដល់ជនរងគ្រោះអំពីតួនាទីរបស់ពួកគេ និងវិសាលភាព ពេលកំណត់ និងការរីកចម្រើននៃកិច្ចដំណើរការនីតិវិធី និងអំពីការសម្រេចសេចក្តីលើរឿងក្តីរបស់ពួកគេ ជាពិសេសនៅពេលមានការពាក់ព័ន្ធនឹងបទឧក្រិដ្ឋ និងនៅពេលដែលពួកគេស្នើសុំព័ត៌មាននេះ។*

*ខ. អនុញ្ញាតឱ្យយកទស្សនៈយល់ឃើញ និងក្តីបារម្ភរបស់ជនរងគ្រោះធ្វើការបង្ហាញ និងពិចារណានៅដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធី នៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវបានប៉ះពាល់ ដោយគ្មានព្យសនកម្មលើជនជាប់ចោទ និងស្របជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលពាក់ព័ន្ធ។*

*គ. ផ្តល់ជំនួយសមស្របដល់ជនរងគ្រោះ តាមរយៈនីតិវិធីច្បាប់។*

---

[១០] James O'Toole "Cayley in the crosshairs" កាសែត Phnom Penh Post ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ១។

[១១] គោលការណ៍ទី៤ នៃ *សេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការរំលោភអំណាច*។

[១២] គោលការណ៍ទី៥ ដូចខាងលើ។

*ឃ. ចាត់វិធានការដើម្បីធ្វើឱ្យមានផលវិបាកតិចតួចបំផុតចំពោះជនរងគ្រោះ ការពារជីវិតឯកជនរបស់ពួកគាត់ ប្រសិនបើចាំបាច់ និងធានាសុវត្ថិភាពរបស់ពួកគាត់ ក៏ដូចជាសុវត្ថិភាពរបស់ក្រុមគ្រួសាររបស់ពួកគាត់ និងសាក្សីនានា ក្នុងនាមពួកគាត់ ឱ្យរួចផុតពីការគំរាមកំហែង និងការសងសឹក។*

*ង. ជៀសវាងការពន្យារពេលមិនចាំបាច់នៅក្នុងការសម្រេចសេចក្តីលើរឿងក្តីនានា និងការអនុវត្តដីកា ឬក្រឹត្យនានាដែលផ្តល់រង្វាន់ដល់ជនរងគ្រោះ* (សេចក្តីបញ្ជាក់បន្ថែម)។

៣៣. តាមរយៈការខកខាននៅក្នុងកាតព្វកិច្ចរបស់ខ្លួនមិនបានធ្វើការជូនដំណឹងដល់សាធារណជន ស្របតាមវិធាន ៥៦ នៃវិធានផ្ទៃក្នុង ស.ច.ស មិនត្រឹមតែបានរំលោភលើគោលការណ៍ទី៦ នៃគោលការណ៍គ្រឹះប៉ុណ្ណោះទេ ថែមទាំងរំលោភលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលស្ថិតនៅក្នុងការគ្រប់គ្រងអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី និងនៅក្នុងការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន។ ជាពិសេស ស.ច.ស បានរំលោភលើវិធាន ២១(គ) នៃវិធានផ្ទៃក្នុង ក្នុងការរក្សាការជូនដំណឹងដល់ជនរងគ្រោះ[១៣] និងកាន់តែទូលំទូលាយជាងនេះទៀត ស.ច.ស បានរំលោភគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌ ស្របតាមច្បាប់អន្តរជាតិ[១៤]។

## *ទឡ្ហីករណ៍ទីពីរ៖*

## *ស.ច.ស រំលោភបំពានវិធាន១៤(១) វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា១០ នៃច្បាប់ អ.វ.ត.ក ថ្មី មាត្រា៥(២) និង(៣) នៃកិច្ចព្រមព្រៀង ដោយខកខានមិនបានបើកកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ឱ្យបានត្រឹមត្រូវ និងដោយឯករាជ្យ*

៣៤. ការបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺផ្អែកលើការខកខានរបស់ ស.ច.ស ក្នុងការបើកកិច្ចស៊ើបសួរឱ្យបានត្រឹមត្រូវ និង*ដោយឯករាជ្យ*

---

[១៣] វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព... ក្នុងបរិបទនេះ៖...(គ) អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី..."។

[១៤] គោលការណ៍ទី៤ និងទី៦ នៃសេចក្តីប្រកាសស្តីពីគោលការណ៍នៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការរំលោភអំណាច។

ទៅលើអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ដែលបានផ្ញើជូនដោយការិយាល័យសហព្រះរាជអាជ្ញា។ ជាពិសេស ស.ច.ស ខកខានមិនបានពិចារណាទៅលើអង្គហេតុដែលបានដាក់ដោយអ្នកដាក់ពាក្យសុំ/ម្ចាស់បណ្ដឹងឧទ្ធរណ៍។

៣៥. ស.ច.ស ខកខានមិនបានបើកកិច្ចស៊ើបសួរទៅដល់ទីកន្លែង នូវទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នានានៃបទឧក្រិដ្ឋនៅក្នុងសំណុំរឿង០០៣ និង០០៤ ជាពិសេសនៅពេលពាក់ព័ន្ធនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍ ពោលគឺនៅក្រុងភ្នំពេញ និងភូមិភាគបូព៌ា។ ការខកខាននេះបានប៉ះពាល់ដល់លទ្ធភាពរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការបញ្ចូលជាភស្តុតាងឱ្យបានរឹងសម្រាប់ពាក្យសុំរបស់ខ្លួន ហើយដែលជាទូទៅវាជាគោលដៅរបស់យុត្តិធម៌ និងការផ្សះផ្សាជាតិផង។

៣៦. ចាប់តាំងពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ មក នៅពេល ស.ច.ស បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងទីបី[១៥] មក រយៈពេលជាង ២០ ខែ បានកន្លងផុតទៅ ដោយពុំមានបើកកិច្ចស៊ើបសួរឱ្យបានត្រឹមត្រូវទេ។ នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១ រយៈពេលជិត ១៧ ខែ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងទីបី និងការបើកកិច្ចស៊ើបសួរមក ស.ច.ស បានជូនព័ត៌មានជាសាធារណៈថា មិនមានការស៊ើបសួរដល់ទីកន្លែងទេ ហើយ *"ភារកិច្ចបច្ចុប្បន្នរបស់ក្រុមការងារទាំងនេះគឺការពិនិត្យ និងវិភាគទៅលើឯកសារនានាដែលមាននៅក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានស្រាប់ក្នុងសំណុំរឿង០០១ និង០០២"*[១៦]។ បន្ទាប់ពីបានចេញសេចក្ដីប្រកាសនេះមួយរយៈខ្លីមក ការបញ្ចប់កិច្ចស៊ើបសួរក៏ត្រូវបានប្រកាសជាសាធារណៈដែរ។ គេអាចសន្និដ្ឋានពីថិរវេលាដ៏ខ្លីពីការប្រកាសជាសាធារណៈនៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១ និងការប្រកាសបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ (តិចជាង ៣ ខែ) ថា មិនមានការស៊ើបសួរដល់ទីកន្លែងទាល់តែសោះ។

៣៧. ដើម្បីសង្កត់ធ្ងន់ពីបញ្ហានេះ "កិច្ចស៊ើបសួរ" របស់ ស.ច.ស ត្រូវបានបញ្ចេញឱ្យដឹងជាមុន ដោយសារចៅក្រមជាតិ លោក យូ ប៊ុនឡេង "មិនចុះហត្ថលេខា" លើដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងសំណុំ

---

[១៥] សូមមើលព័ត៌មានសាធារណៈ នៅគេហទំព័រ៖ http://www.eccc.gov.kh/en/articles/acting-international-co-prosecutor-requests-investigation-additional-suspects ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩។

[១៦] សូមមើលសេចក្ដីថ្លែងការណ៍ជាសាធារណៈ នៅគេហទំព័រ៖ http://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-files-003-and-004 ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។

រឿង០០៣ និង០០៤[១៧]។ បន្ទាប់ពីចៅក្រមស៊ើបអង្កេតអន្តរជាតិកំណត់កាលបរិច្ឆេទចុងក្រោយដល់សមភាគីជាតិរបស់ខ្លួននៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១០ ដើម្បីចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួសនោះ នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១០ អ្នកនាំពាក្យផ្នែកកិច្ចការច្បាប់អង្គការសហប្រជាជាតិ Lars Olsen បានមានប្រសាសន៍ថា "ការស៊ើបអង្កេតជំហានដំបូងសម្រាប់សំណុំរឿង ០០៣ និង ០០៤ [បាន]ចាប់ផ្តើមពីថ្ងៃ សុក្រ [ទី ៤ ខែ មិថុនា ឆ្នាំ ២០១០] ជាសម្ងាត់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស [...] ដែលត្រូវបានចុះហត្ថលេខាដោយសហចៅក្រម*ទាំងពីរ*"[១៨]។

៣៨. ការឆ្លើយតបក៏បានធ្វើភ្លាមៗដែរថា៖ "អ្នកនាំពាក្យក្រសួងមហាផ្ទៃ [រាជរដ្ឋាភិបាលកម្ពុជា] ឧត្តមសេនីយ៍ឯក ខៀវ សុភ័គ បានបញ្ជាក់ជាថ្មីនូវការជំទាស់របស់រដ្ឋាភិបាលទៅលើការស៊ើបអង្កេតថ្មី [...] ដោយដកស្រង់ការព្រមានរបស់សម្តេច ហ៊ុន សែន ពីការបះបោរ៖ "មិនមែន ៦ នាក់ទេ គឺតែ ៥ នាក់ទេ។ តុលាការត្រូវធានានូវស្ថិរភាព និងសន្តិភាពជាតិ។ យើងមិនចង់មានជម្លោះ និងអស្ថិរភាពផ្ទៃក្នុងទេ"[១៩]។

៣៩. នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ចៅក្រម យូ ប៊ុនឡេង បានលុបហត្ថលេខារបស់គាត់ និងបានបញ្ជូនដីកាចាត់ឱ្យស៊ើបសួរជំនួសត្រឡប់មកចៅក្រម Lemonde វិញ ដោយបញ្ជាក់ថា គាត់លែងគាំទ្រដល់ការស៊ើបអង្កេតនេះទៀតហើយ។ "ខ្ញុំបានចំណាយពេលពិចារណាម្តងហើយម្តងទៀត អំពីកាលានុវត្តភាពនៃចំណាត់ការលើសំណុំរឿង០០៣ និង ០០៤ នេះ"[២០]។

---

[១៧] អនុស្សរណៈផ្ទៃក្នុង ក.ស.ច.ស ពីចៅក្រម យូ ប៊ុនឡេង ទៅចៅក្រម Marcel Lemonde ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ re 'Dossiers 003 et 004' (បកប្រែក្រៅផ្លូវការពីភាសាបារាំងជាភាសាដើម)។

[១៨] Douglas Gillison "សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតលើជនសង្ស័យថ្មីចំនួន ៥ នាក់ នៃរបបខ្មែរក្រហម" *កាសែតខឹមបូឌាដេលី* ចេញផ្សាយថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ២៦ (គូសបញ្ជាក់បន្ថែម)។ នៅពេលរសៀលនាថ្ងៃដដែលនោះ លោក រាជ សម្បត្តិ ដែលជាអ្នកនាំពាក្យកម្ពុជាសម្រាប់សាលាក្តី "បានចេញសេចក្តីថ្លែងការណ៍មួយប្រកាសពីការដកខ្លួនរបស់ចៅក្រម យូ ប៊ុនឡេង មិនចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួស ហើយនិយាយថា អត្ថបទសារព័ត៌មានដែលនិយាយពីការចុះហត្ថលេខាលើឯកសារទាំងនេះ ដែលផ្អែកលើព័ត៌មានដែលបានផ្តល់ដោយលោក Olsen ដែលជាអ្នកនាំពាក្យអង្គការសហប្រជាជាតិ ជា "ព័ត៌មានដែលពុំមានមូលដ្ឋានត្រឹមត្រូវ។

[១៩] *ដូចជើងទំព័រខាងលើ*។

[២០] អនុស្សរណៈផ្ទៃក្នុង ក.ស.ច.ស ពីចៅក្រម យូ ប៊ុនឡេង ផ្ញើជូនចៅក្រម Marcel Lemonde ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ re 'Dossiers 003 et 004' (បកប្រែក្រៅផ្លូវការពីភាសាបារាំងជាភាសាដើម)។

៤០. នៅខែ មិថុនា ឆ្នាំ ២០១០ គម្រោងយុត្តិធម៌សង្គមសេរី (OSJI) ដែលជាអង្គការមួយដែលមានឈ្មោះបោះសំឡេងក្នុងការតាមដានដំណើរការតុលាការ បានចេញផ្សាយរបាយការណ៍របស់ខ្លួន ដែលវាយតម្លៃចំពោះ "ការមិនចុះហត្ថលេខា" ថា៖

*លោកចៅក្រម យូ ប៊ុនឡេង ជាដំបូងបានចុះហត្ថលេខាអនុញ្ញាតឱ្យមានការស៊ើបអង្កេតទាំងនេះ ប៉ុន្តែក្រោយមកបន្តិចបានលុបចោលការយល់ព្រមរបស់លោក បន្ទាប់ពីដីកានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់សាជាថ្មីជាសាធារណៈថា "មានតែមេដឹកនាំកំពូលចំនួនប្រាំរូបប៉ុណ្ណោះត្រូវទទួលការកាត់ទោស"។ លោកចៅក្រម យូ ប៊ុនឡេង បានលើកយក "ស្ថានភាពបច្ចុប្បន្ននៃសង្គមកម្ពុជា" មកធ្វើជាមូលហេតុសម្រាប់ការច្រានចោលនូវការយល់ព្រម ចំពោះការស៊ើបអង្កេតណាមួយទៅលើសំណុំរឿង។ លោកបានចង្អុលបង្ហាញថា ការស៊ើបអង្កេតទៅលើសំណុំរឿងណាមួយ នឹងត្រូវពិចារណាម្តងទៀតបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ [សម្រាប់សំណុំរឿង ០០២]។* ***ទាំងនេះគឺជាសេចក្តីទាមទារផ្នែកនយោបាយយ៉ាងជាក់ច្បាស់។*** *ដោយបន្ថែមទៅលើប្រវត្តិដែលរដ្ឋាភិបាលបានបដិសេធមិនឱ្យសំណុំរឿង០០៣/០០៤ ធ្វើដំណើរទៅមុខដោយឯករាជ្យនោះ ប្រការនេះគាំទ្រដល់ការសន្និដ្ឋានដែលថា ការជ្រៀតជ្រែកផ្នែកនយោបាយបានធ្វើឱ្យប៉ះពាល់ដោយមិនត្រឹមត្រូវទៅលើការសម្រេចចំពោះសំណុំរឿងទាំងនេះ*[២១]។ (គូសបញ្ជាក់បន្ថែម)

៤១. នៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានថ្លែងពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតថា *"ពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របនៃចំណាត់ការស៊ើបសួរ"* និងថា *"សម្រាប់រយៈពេលរហូតដល់ដំណាច់ឆ្នាំនេះ ចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារនេះតែម្នាក់ឯងដោយអនុលោមតាមបញ្ញត្តិនៃវិធាន៧២"*[២២]។

---

[២១] អង្គការ OSJI "ការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ មិថុនា ឆ្នាំ ២០១០ អាចរកបាននៅគេហទំព័រ៖ http://www.soros.org/initiatives/justice/focus/international_jurstice/articles_publications/publications/political-interference-report-20100706, ទំព័រ២១ (គូសបញ្ជាក់បន្ថែម)។

[២២] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត នៅគេហទំព័រ៖ http://old.eccc.gov.kh/english/cabinet/press/156/PROCIJ%28JUne2010.pdf។

៤២. បណ្ដាអ្នកសង្កេតការណ៍បានសន្និដ្ឋានថា "*ការខ្វែងយោបល់ស៊ីសង្វាក់គ្នានឹងការរួញរារបស់រដ្ឋាភិបាលក្នុងការជំនុំជម្រះក្ដីអតីតមេដឹកនាំរបបនេះ ក្រៅពីមនុស្ស ៥ រូប [ដែលកំពុងស្ថិតក្នុងការឃុំឃាំងនេះ]*"[២៣] និង "*ពេលនេះចៅក្រម Marcel Lemonde កំពុងដំណើរការ ដោយគ្មានការគាំទ្រពីសហសេវិកកម្ពុជាក្នុងការស៊ើបអង្កេតដែលមានការចោទប្រកាន់ផ្នែកនយោបាយ ដែលមន្ត្រីរដ្ឋាភិបាលធ្លាប់បាននិយាយថាមិនគួរនឹងបន្តទៅមុខទៀតទេ*"[២៤]។

៤៣. ទោះបីក្រោយពេលដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ត្រូវបានចេញនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក៏ដោយ ក៏កិច្ចស៊ើបសួរត្រឹមត្រូវ ដូចជា ការស៊ើបសួរទៅដល់ទីកន្លែង ការស្ដាប់ចម្លើយសាក្សី ជនរងគ្រោះ និងការសួរចម្លើយជនសង្ស័យ មិនទាន់បានធ្វើនៅឡើយទេ។

៤៤. ស.ច.ស ខកខានមិនបានបំពេញតួនាទី មុខងារ និងកាតព្វកិច្ចរបស់ខ្លួនតាមផ្លូវច្បាប់អនុលោមតាមច្បាប់ អ.វ.ត.ក ទេ ដែលចែងថា៖

> *"រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ...។ សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្ដាប់ចម្លើយសាក្សី និងប្រមូលភស្ដុតាង ដោយអនុវត្តតាមនីតិវិធីជាធរមាន ..."*[២៥] ។

ស.ច.ស មិនបានរៀបចំកិច្ចស៊ើបសួរថ្មីនៅក្នុងសំណុំរឿង០០៣ ទេ ហើយគ្រាន់តែយោងទៅដល់សម្ភារៈដែលមានស្រាប់ក្នុងសំណុំរឿង០០១ និង០០២ ប៉ុណ្ណោះ។ សំណុំរឿង០០១ និង០០២ ពាក់ព័ន្ធនឹងជនសង្ស័យ ៥ រូប ផ្សេងទាំងស្រុង ហើយវិធីសាស្ត្ររបស់ ស.ច.ស ក្នុងកិច្ចស៊ើបសួរមិនសមហេតុផលឡើយ ហើយមិនបានបង្ហាញពីឆន្ទៈ ឬមានបំណងចង់អនុវត្តមុខងាររបស់ខ្លួនឱ្យពេញលេញ ត្រឹមត្រូវ និងឯករាជ្យទេ។ ស.ច.ស មិនបានអនុវត្តតាម "នីតិវិធីជាធរមាន" ដែលរួម

---

[២៣] Sebastian Strangio, "ចៅក្រមនៅសាលាក្ដីខ្មែរក្រហមខ្វែងគំនិតគ្នានៅក្នុងសំណុំរឿងបន្ទាប់" *កាសែតភ្នំពេញប៉ុស្ដិ៍* ចេញផ្សាយថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ១។

[២៤] Douglas Gillison, "មានសំណួរច្រើនជាងចម្លើយ" *កាសែតខេមបូឌាដេលី* ចេញផ្សាយថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ២៧។

[២៥] ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា២៣ ទំព័រ៩។

មានការសួរចម្លើយជនសង្ស័យ និងការស្តាប់ចម្លើយជនរងគ្រោះ សាក្សី និងប្រមូលភស្តុតាងទេ។ ពួកគេមិនចាត់ការបំពេញការងារទាំងអស់នេះទេ ហេតុនេះហើយពួកគេខកខានមិនបានអនុវត្តការទទួលខុសត្រូវផ្នែកច្បាប់ក្នុងនាមជា ស.ច.ស ឡើយ។

៤៥. ការខកខានមិនបានបើកកិច្ចស៊ើបសួរឱ្យបានពេញលេញ និងត្រឹមត្រូវទំនងជាមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងសេចក្តីថ្លែងការណ៍ដែលជាសាធារណៈរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន រួមទាំងការជម្រាបប្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ដែលបានមកបំពេញទស្សនកិច្ចកាលពីខែ តុលា ឆ្នាំ ២០១០ ថា "ការកាត់សេចក្តីលើកទីពីរចំពោះពួកខ្មែរក្រហមស្តីពីបទឧក្រិដ្ឋសង្គ្រាមនឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយ នឹងជាការកាត់សេចក្តីចុងក្រោយ។ សម្តេច ហ៊ុន សែន បានបញ្ជាក់យ៉ាងច្បាស់ថា មិនអនុញ្ញាតឱ្យមានសំណុំរឿង០០៣ ទេ"។ រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង បានប្រាប់បណ្តាអ្នកយកព័ត៌មានបន្ទាប់ពីជំនួបរវាងអគ្គលេខាធិការអង្គការសហប្រជាជាតិ និងលោកនាយករដ្ឋមន្ត្រីថា "យើងត្រូវគិតដល់សន្តិភាពនៅកម្ពុជា"[២៦]។ អង្គការ OSJI បានវាយតម្លៃសេចក្តីថ្លែងការណ៍នាពេលថ្មីៗនេះថា៖

> *ការជ្រៀតជ្រែកផ្នែកនយោបាយទៅក្នុងកិច្ចការរបស់តុលាការ យ៉ាងឥតលាក់លៀមបែបនេះ គឺពិតជាផ្ទុយទៅនឹងបទដ្ឋានជាមូលដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌*[២៧] *និងជាការអនុវត្តជាក់ស្តែង មន្ត្រីតុលាការកម្ពុជាមិនមានសេរីភាពក្នុងការដំណើរការជំនុំជម្រះឡើយ ដោយសារ [នាយករដ្ឋមន្ត្រី] បានជំទាស់ជាចំហ និងដាច់អហង្ការបែបនេះ។ មន្ត្រីតុលាការ*

---

[២៦] សេចក្តីរាយការណ៍របស់កាសែត AFP "នាយករដ្ឋមន្ត្រីកម្ពុជានិយាយថា គ្មានការជំនុំជម្រះខ្មែរក្រហមលើកទីបីទេ" ចេញផ្សាយថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០។ របាយការណ៍របស់អង្គការ OSJI "ការជួយស្រោចស្រង់ឯករាជ្យភាពវិស័យតុលាការ" ខែ វិច្ឆិកា ឆ្នាំ ២០១០ អាចរកបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-20101110/cambodia-khmer-rouge-20101110.pdf។

[២៧] របាយការណ៍របស់អង្គការ OSJI "ការជួយស្រោចស្រង់ឯករាជ្យភាពវិស័យតុលាការ" ខែ វិច្ឆិកា ឆ្នាំ ២០១០ អាចរកបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/khmer-rouge-tribunal-20101110/cambodia-khmer-rouge-20101110.pdf។

*កម្ពុជាមានការភ័យខ្លាចមិនប៊ានធ្វើសកម្មភាពរឹងទទឹង ទៅនឹងបញ្ហាជាសាធារណៈរបស់ប្រមុខរដ្ឋឡើយ*[២៨]។

៤៦. ចៅក្រមកម្ពុជាមួយរូបនៅ អ.វ.ត.ក បានប្រាប់ James Goldston ដែលជានាយកប្រតិបត្តិអង្គការ OSJI កាលពីដើមខែ កុម្ភៈ ឆ្នាំ ២០១០ ចំពោះបញ្ហានានាដែលនៅចំពោះមុខថា៖ *"តើយើងអាចថាតុលាការនេះជាគំរូតុលាការឯករាជ្យដូចម្ដេចបាន បើរដ្ឋាភិបាលមិនឱ្យយើងធ្វើការងារយើងផងនោះ?"*[២៩]។

៤៧. ឧទាហរណ៍មួយទាក់ទិននឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាល ទៅក្នុងកិច្ចការតុលាការនាពេលថ្មីៗ ក្នុងសំណុំរឿង០០២ គឺនៅពេលដែល ក.ស.ច.ស ខកខានមិនបានស្ដាប់ចម្លើយសាក្សីសំខាន់ៗ ដែលត្រូវបានគេណែនាំមិនឱ្យអនុវត្តតាមដីកាកោះហៅរបស់តុលាការ។ បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី[៣០] ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានថ្លែងថា "ទោះបី ក.ស.ច.ស ជាស្ថាប័នរួបរ័ន្តផ្នែកស៊ើបអង្កេតនៅ អ.វ.ត.ក ក៏ដោយ ក៏ពួកគេបានបដិសេធម្ដងហើយម្ដងទៀត មិនបើកកិច្ចស៊ើបសួរលើបញ្ហានេះ [ការចោទប្រកាន់ពីការជ្រៀតជ្រែក]"។ ចៅក្រមអន្តរជាតិក៏បានសន្និដ្ឋានថា *"យោបល់របស់លោក ខៀវ កាញារិទ្ធ ធ្វើឱ្យយើងជឿថា មានហេតុផលជឿថា គាត់ ឬ បុគ្គលដែលគាត់ផ្ដល់យោបល់ដោយជំនួសមុខឱ្យនោះ អាចប៉ុនប៉ងដោយចេតនាពិតប្រាកដ នៅក្នុងការគំរាមកំហែង ឬ បំភិតបំភ័យមន្ត្រីទាំង ៦ រូប ឬ បើមិនដូច្នោះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំង ៦ រូបនេះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យមកផ្ដល់សក្ខីកម្ម"*[៣១]។

---

[២៨] របាយការណ៍របស់អង្គការ OSJI "ការវិវឌ្ឍន៍ថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ ធ្នូ ឆ្នាំ ២០១០ ធ្វើបច្ចុប្បន្នភាព អាចរកបាននៅ៖ http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/cambodia-report-20101207/cambodia-khmer-rouge-report-20101207.pdf។

[២៩] James Goldston, "តុលាការកម្ពុជានៅលើផ្លូវក្រឡែងកែង" *The Wall Street Journal,* ចេញផ្សាយថ្ងៃទី ១ មីនា ឆ្នាំ ២០១០។

[៣០] សាលដីកាលើកទីពីរលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12 ទំព័រ២១។

[៣១] *ដូចជើងទំព័រខាងលើ*។

៤៨. ជាងនេះទៀត ដោយសារការិយាល័យអ្នកស៊ើបអង្កេតនឹងត្រូវបិទទ្វារបញ្ចប់ការងារ ហើយអ្នកស៊ើបអង្កេតអង្គការសហប្រជាជាតិបានទទួលព័ត៌មានថា កិច្ចសន្យាការងាររបស់ខ្លួននឹងមិនបន្តហួសពីចុងឆ្នាំនេះទេ[៣២] នោះ វាកាន់តែទំនងជាលេចឡើងថា ទោះបីមានសំណើសុំឱ្យស៊ើបសួរបន្ថែមពីការិយាល័យសហព្រះរាជអាជ្ញាក៏ដោយ ក៏សំណើទាំងនោះនឹងត្រូវគេបដិសេធចោលដែរ ដោយមិនរំពឹងថានឹងមានឱកាសប្តឹងឧទ្ធរណ៍ទេ ដោយសារការបិទការិយាល័យ ស.ច.ស ត្រូវបានសម្រេចរួចទៅហើយ។

៤៩. សរុបមក ការខកខានមិនបានបើកកិច្ចស៊ើបសួរដោយឯករាជ្យ និងពេញលេញ និងការជៀសផុតពីការហាមឃាត់របស់នាយករដ្ឋមន្ត្រីមិនឱ្យមានការស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ នោះ ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោលគ្មានការស៊ើបសួរអ្វីទាំងអស់។ អាស្រ័យហេតុនេះ ដីកាសម្រេចបដិសេធនេះមានវិការៈ ហើយជាការរំលោភបំពានដល់វិធាន១៤(១) វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា១០ថ្មី នៃច្បាប់ អ.វ.ត.ក និង មាត្រា៥(២) និង (៣) នៃកិច្ចព្រមព្រៀង ផងដែរ។

***ទឡ្ហីករណ៍ទីបី៖***

***ស.ច.ស អនុវត្តមិនបានត្រឹមត្រូវ និងបកស្រាយមិនបានត្រឹមត្រូវនូវអង្គហេតុ និងអង្គច្បាប់ ជាពិសេស គោលការណ៍សហឧក្រិដ្ឋកម្មរួម និងផែនរួម/គោលបំណងរួម***

៥០. ស.ច.ស អនុវត្តមិនបានត្រឹមត្រូវ និងបកស្រាយមិនបានត្រឹមត្រូវនូវអង្គហេតុ និងអង្គច្បាប់ ឧទាហរណ៍ គោលការណ៍ "សហឧក្រិដ្ឋកម្មរួម" និង "ផែនការរួម និងគោលបំណងរួម"។

៥១. ម្ចាស់បណ្តឹងឧទ្ធរណ៍សូមលើកឡើងជាទឡ្ហីករណ៍ថា [redacted] ត្រូវ "**ទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល**" ក្នុងសមត្ថភាពពីរគឺ៖ (i) ពួកគេបានចូលរួមចំណែកដោយបានដឹង ដោយផ្ទាល់ និងជាសំខាន់ចំពោះបទឧក្រិដ្ឋដែលស្ថិតក្នុងកិច្ចស៊ើបសួរ ដែលរូបនាងជាជនរងគ្រោះ និងជាសាក្សីមួយរូប (ជា "**ការទទួលខុសត្រូវជាលក្ខណៈបុគ្គល**") និង (ii) ពួកគេបានដឹង ហើយខកខានមិនបានរារាំងបទឧក្រិដ្ឋដែលបានប្រព្រឹត្តប្រឆាំងរូបនាង (ជា "**ការទទួលខុសត្រូវរបស់ថ្នាក់លើ**")។

---

[៣២] Julia Wallace, "ការស៊ើបអង្កេតសំណុំរឿង០០៣ បានបញ្ចប់ហើយ" *ព្រឹត្តិប័ត្រព័ត៌មានខ្មែរកម្ពុជាដេលី* ចេញផ្សាយថ្ងៃទី ២០ ខែ មេសា - ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ២។

៥២. ដូចគ្នានេះដែរ ម្ចាស់បណ្ដឹងឧទ្ធរណ៍សូមលើកឡើងជាទឡ្ហីករណ៍ថា ដោយសារវាជាបញ្ហាមួយនៅក្នុងច្បាប់អន្តរជាតិ [redacted] មានការទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្មរបស់នាងតាមផ្លូវច្បាប់ ក្នុងអំឡុងពេលដែលក្រុងភ្នំពេញបានដួលរលំ និងការជម្លៀសប្រជាជនចេញពីទីក្រុង (ការជម្លៀសនៅដំណាក់កាលទី១) នៅពេលដែលឪពុកនាង ដែលជាអតីតមេបញ្ជាការម្នាក់ក្នុងកងទ័ព លន់ នល់ "បានបាត់ខ្លួន" ក្នុងចំណោមព្យសនកម្មតាមផ្លូវច្បាប់ដទៃទៀត និងការជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ា (ការជម្លៀសនៅដំណាក់កាលទី៣) នៅពេលដែលពួកខ្មែរក្រហមដាក់នាង និងគ្រួសាររបស់នាងក្នុងមន្ទីរឃុំឃាំង ដំបូងនៅ **មន្ទីរសន្តិសុខវត្តធ្លក** (Wat Tlork) **និងបន្ទាប់មកនៅមន្ទីរសន្តិសុខបឹងរៃ** (Boeung Rai) ដែលនៅទីនោះ នាងបានឆ្លងកាត់បទពិសោធន៍ និងបានឃើញផ្ទាល់ភ្នែក *ក្នុងចំណោមនោះ* មានការស្លាប់ម្ដាយនាង ក្នុងចំណោមប្រជាជនប្រមាណ ៣០.០០០ (សាមសិបពាន់) នាក់ដែលទំនងជាត្រូវបានយកទៅកម្ទេចនៅបឹងរៃ។

៥៣. ត្រង់ចំណុចនេះ **ចំណងទាក់ទងតាមផ្លូវច្បាប់ចំពោះម្ចាស់បណ្ដឹងឧទ្ធរណ៍គឺ** បទឧក្រិដ្ឋ មិនមែនទីតាំងភូមិសាស្ត្រនៃស្រុក និងភូមិភាគដែលជនត្រូវចោទទាំងនេះគ្រប់គ្រងដោយផ្ទាល់នោះទេ។

៥៤. ជាងនេះទៀត ដីកាសម្រេចលើការទទួលយកពាក្យសុំតម្រូវឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍បង្ហាញពីទំនាក់ទំនងបទឧក្រិដ្ឋ *តែមួយប៉ុណ្ណោះ* (*"យ៉ាងហោចណាស់បទឧក្រិដ្ឋមួយ"* វិធាន២៣*ស្ទួន*) ដែលនាងបានទទួល [redacted] ដើម្បីឱ្យគេទទួលយក។ ដូចគ្នានេះដែរ គេពិបាកនឹងជឿថា [redacted] មិនបានចូលរួមចំណែកផ្នែកសម្ភារៈក្នុងការផ្ដួលរំលំក្រុងភ្នំពេញ និងការជម្លៀសប្រជាជនចេញពីក្រុង (ការជម្លៀសនៅដំណាក់កាលទី១) ទេ នៅពេលដែល *ក្នុងចំណោមនោះ* ម្ចាស់បណ្ដឹងឧទ្ធរណ៍បានបាត់បង់ឪពុក ឬថា ពួកគេមិនបានចូលរួមចំណែកផ្នែកសម្ភារៈក្នុងការការឃុំឃាំងម្ចាស់បណ្ដឹងឧទ្ធរណ៍នៅមន្ទីរសន្តិសុខវត្តធ្លក និងមន្ទីរសន្តិសុខបឹងរៃ ក្នុងអំឡុងពេលមានការសម្រិតសម្រាំងនៅភូមិភាគបូព៌ា និងការចូលលុកលុយទៅក្នុងប្រទេសវៀតណាមនោះទេ។

**ទឡ្ហីករណ៍ទីបួន៖**

***ក្នុងការខកខានមិនបានផ្ដល់នូវសំអាងហេតុត្រឹមត្រូវ ទាក់ទិននឹងពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ចំពោះករណី [redacted] នោះ ស.ច.ស បានរំលោភបំពានចំពោះវិធាន២១ ដែលទាក់ទិននឹងគោលការណ៍មូលដ្ឋាន នៃភាពយុត្តិធម៌ផ្នែកនីតិវិធី ក្នុងការផ្ដល់សំអាងហេតុសម្រាប់ការចេញសេចក្ដីសម្រេច***

៥៥. ស.ច.ស ខកខានមិនបានចេញសេចក្ដីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ ក្នុងការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ចំពោះករណី [redacted] ជាងនេះទៀត ស.ច.ស មានកំហុសឆ្គងដោយចេតនា ដោយគ្រាន់តែថ្លែងថា *"មិនមានស្ថានភាពអង្គហេតុណាមួយ ក្នុងចំណោមស្ថានភាពអង្គហេតុដែលបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងអង្គហេតុដែលមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងលើកទីបី នោះទេ"* ដោយមិនបានរៀបរាប់ពីរបៀបដែល "ស្ថានភាពអង្គហេតុ" របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍នៅក្រុងភ្នំពេញ និងដំណាក់កាលទី១ នៃការជម្លៀសប្រជាជន ភូមិភាគបូព៌ា (រួមទាំងនៅមន្ទីរសន្តិសុខវត្តធ្លក និងមន្ទីរសន្តិសុខបឹងរ៉ៃ) និងដំណាក់កាលទី៣ នៃការជម្លៀសប្រជាជន មិន "ពាក់ព័ន្ធនឹងអង្គហេតុសម្ភារៈ" ក្នុងសំណុំរឿង០០៣ និង០០៤ ទេ នៅពេលដែល ស.ច.ស ខកខានមិនបានរៀបរាប់ពីអង្គហេតុសម្ភារៈ និងវិសាលភាពនៃកិច្ចស៊ើបសួរនោះ។

៥៦. កាតព្វកិច្ចក្នុងការចេញដីកាសម្រេច *ដែលមានសំអាងហេតុត្រឹមត្រូវ* គឺជាភារកិច្ចដែលស្ថាប័នតុលាការត្រូវអនុវត្ត។ ទោះបីវិធានផ្ទៃក្នុងបច្ចុប្បន្នមិនបានចែងបញ្ជាក់ពីលក្ខខណ្ឌតម្រូវនេះក៏ដោយ តែច្បាប់ អ.វ.ត.ក អនុញ្ញាតឱ្យ អ.ប.ជ ត្រូវស្វែងរកការណែនាំក្នុងវិធាននីតិវិធីនៅតុលាការអន្តរជាតិបាន[៣៣]។

---

[៣៣] សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ថា វិធាន២៣(៣) និង(៤) (វិសោធនកម្មលើកទីបី និងវិសោធនកម្មលើកមុនៗ) ចែងថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានការសម្រេចដោយមានសំអាងហេតុត្រឹមត្រូវ ទាក់ទិននឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំ។ វិធាន២៣(៣) ចែងថា៖ "... *សហចៅក្រមស៊ើបអង្កេត អាចសម្រេចចេញដីកា ដោយមានសំអាងហេតុ បដិសេធពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន (...)*"។ វិធាន២៣(៤) ចែងថា៖ "... *អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចតាមរយៈសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុ ថាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ មិនអាចទទួលយកបាន*"។ ចំណុចនេះបង្ហាញថា សំណៅមុននៃវិធានផ្ទៃក្នុងបានបញ្ជាក់ពីសិទ្ធិជាសារវ័ន្តរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ សិទ្ធិនេះស្ថិតនៅជាគោលការណ៍មូលដ្ឋាននៃភាពយុត្តិធម៌ផ្នែកនីតិវិធី។

៥៧. សិទ្ធិទទួលបានការសម្រេចសេចក្តីយ៉ាងយុត្តិធម៌ ចំពោះបញ្ហាណាមួយត្រូវបានការពារដោយមាត្រា ១៤.១ នៃ ICCPR[៣៨]។ ការខកខានរបស់ ស.ច.ស មិនបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុសមរម្យជាការបដិសេធយ៉ាងច្បាស់ចំពោះសិទ្ធិទទួលបានការសម្រេចសេចក្តី យ៉ាងយុត្តិធម៌ ជាពិសេសគឺសិទ្ធិទទួលបានមូលហេតុច្បាស់លាស់ ចំពោះការប្រកាសមិនទទួលយកពាក្យសុំរបស់ខ្លួន និងជាងនេះទៅទៀត គឺសិទ្ធិទទួលបានសវនាការដែលសមរម្យ ដោយសារថាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចឆ្លើយតបទៅនឹងការបដិសេធដោយមិនបានដឹងពីសំអាងហេតុ។

៥៨. ពេលនេះយើងបានដឹងហើយថា បើតាមការបំភ្លឺជាក់លាក់ជាសាធារណៈដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley នូវបទឧក្រិដ្ឋនានា ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នៃបទឧក្រិដ្ឋនោះ បានបង្ហាញឱ្យឃើញថា ស.ច.ស មិនបានបង្ហាញពីភាពស្មោះត្រង់ជាចំហទេ ដោយពួកគេបែរជារៀបរាប់នៅក្នុងដីកាសម្រេចរបស់ខ្លួនថា កង្វះខាតអង្គហេតុសម្ភារៈទៅវិញ។ បទឧក្រិដ្ឋ និងព្រឹត្តិការណ៍នានានៃបទឧក្រិដ្ឋនៅភូមិភាគបូព៌ា គឺជាផ្នែកមួយនៃការសម្រិតសម្រាំង និងការចូលលុកលុយទៅក្នុងប្រទេសវៀតណាម ដែលបានប្រព្រឹត្តដោយ [redacted] ដែលបានប៉ះពាល់ដល់ផ្នែករូបវ័ន្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គឺពិតជាមានទំនាក់ទំនងដោយផ្ទាល់ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលពេលនេះត្រូវបានបញ្ជាក់គាំទ្រដោយមិនអាចប្រកែកបាន។

៥៩. ទាក់ទិននឹងបញ្ហានេះដែរ ស.ច.ស ក៏មានកំហុសឆ្គងជាចំហដែរដោយអះអាងថា *"[ស្ថានភាពនៃអង្គហេតុរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍] ក៏មិនពាក់ព័ន្ធនឹងកាលៈទេសៈផ្សេងៗជុំវិញអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬក៏មិនទំនងជាមានប្រយោជន៍ដល់ការកំណត់ពីធាតុផ្សំយុត្តាធិការ និងអំពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ នោះដែរ"*។

៦០. កង្វះខាតសំអាងហេតុសមរម្យ និងពិស្តារបែបនេះបានបង្កើតជាកំហុសឆ្គងលើអង្គច្បាប់ និងធ្វើឱ្យដីកាសម្រេចបដិសេធមិនមានសុពលភាពទេ។ ការផ្តល់សំអាងហេតុមិនពេញលេញគ្រប់គ្រាន់នោះ

[៣៨] មាត្រា១៤.១ នៃ ICCPR ចែងថា៖ "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។"

រំលោភទៅដល់គោលការណ៍ជាសារវ័ន្តនៃច្បាប់ដែលថា ត្រូវផ្តល់សំអាងហេតុត្រឹមត្រូវសម្រាប់សេចក្តីសម្រេចណាមួយតាមផ្លូវតុលាការ។ ជាងនេះទៀត វាធ្វើឱ្យសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការប្តឹងឧទ្ធរណ៍ តាមវិធាន៧៤(៤) និង៧៧*ស្ទួន* ក្លាយជារឿងគ្មានន័យ ដោយផ្អែកលើមូលដ្ឋានថា មិនមានព័ត៌មានគ្រប់គ្រាន់ដែលអាចឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍អាចសម្រេចធ្វើជាមូលដ្ឋានសម្រាប់ប្តឹងឧទ្ធរណ៍ទៅ អ.ប.ជ។ ស្រដៀងគ្នានេះដែរ ការផ្តល់សំអាងហេតុមិនពេញលេញ និង/ឬ មិនគ្រប់គ្រាន់ មិនបានផ្តល់ឱ្យ អ.ប.ជ នូវកម្រិតនៃព័ត៌មានមួយដែលអាចយកទៅប្រើប្រាស់ ដើម្បីពិនិត្យពិចារណាទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធនោះឱ្យបានសមរម្យ និងមានប្រសិទ្ធភាពឡើយ។

៦១. មាត្រា៤៥ § ១ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅទ្វីបអឺរ៉ុប (“**អនុសញ្ញា ECHR**”) ចែងថា *“ត្រូវផ្តល់សំអាងហេតុសម្រាប់ការវិនិច្ឆ័យណាមួយ រួមទាំងសម្រាប់សេចក្តីសម្រេចដែលប្រកាសថាពាក្យសុំណាមួយត្រូវបានទទួលយក ឬ មិនទទួលយក”*។ មាត្រាបញ្ជាក់ពីគោលការណ៍សារវ័ន្តរបស់ច្បាប់។ ដោយយោងទៅដល់មាត្រា ៦ § ១ នៃអនុសញ្ញានេះ តុលាការសិទ្ធិមនុស្សនៅទ្វីបអឺរ៉ុប (“ECHR”) ក៏បានតម្កល់នូវសេចក្តីសម្រេចជាច្រើនដែលថា “**អនុលោមតាមច្បាប់យុត្តិសាស្ត្ររបស់ខ្លួនដែលបានសម្រេចរួចហើយ សាលក្រម/សាលដីការបស់តុលាការ និងសាលាជម្រះក្តីគួរតែបញ្ជាក់ឱ្យបានពេញលេញនូវសំអាងហេតុដែលខ្លួនពឹងផ្អែកជាមូលដ្ឋាន**”[៣៥]។ ប្រការនេះកើតឡើងដោយសារ *“ការផ្តល់សំអាងហេតុបែបនេះមានសារៈសំខាន់ចំពោះគុណភាពនៃយុត្តិធម៌ និងផ្តល់នូវការការពារប្រឆាំងនឹងការបំពារបំពាននានា”*[៣៦]។ តុលាការអន្តរជាតិដទៃទៀត រួមទាំង អ.វ.ត.ក ផង បានតម្កល់លក្ខខណ្ឌតម្រូវជាសារវ័ន្តនេះដែរ[៣៧]។

[៣៥] *រឿងក្តី* Taxquet *តទល់នឹង ប្រទេសប៊ែលហ្ស៊ិក* ពាក្យសុំលេខ 926/05 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០០៩ កថាខណ្ឌ៤០។

[៣៦] *ដូចដើងទំព័រខាងលើ* ត្រង់កថាខណ្ឌ៤៣។

[៣៧] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ត្រង់កថាខណ្ឌ២៧ ដោយដកស្រង់ពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់តុលាការ ICTY ដែលមិនបានផ្តល់ព័ត៌មានបន្ថែមទៀតជាងដកស្រង់ចេញពីសាលដីកាណាទេ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានសម្រេចថា សិទ្ធិទទួលបានការសម្រេចសេចក្តីដោយមានសំអាងហេតុត្រឹមត្រូវ គឺជាធាតុផ្សំមួយនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយថា មានតែមូលដ្ឋាននៃសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវទេដែលនឹងជួយឱ្យការពិនិត្យពិចារណាទៅលើបណ្តឹងឧទ្ធរណ៍អាចប្រព្រឹត្តទៅបានយ៉ាងត្រឹមត្រូវ (សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolic សាលដីកាទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីការផ្តន្ទាទោស ថ្ងៃទី ៨ ខែ មីនា

៦២. អ.ប.ជ របស់ អ.វ.ត.ក បានអនុម័តនូវលក្ខខណ្ឌតម្រូវនេះពី ECHR ហើយគួរតែបន្តអនុវត្តវាក្នុងករណីនេះផង[៣៨]។ ក្នុងការសម្រេចជាឯកច្ឆន្ទមួយ អ.ប.ជ បានសម្រេចថា ទោះបីច្បាប់យុត្តិសាស្ត្រ ECHR ខាងលើប្រើសម្រាប់តែការចេញសាលក្រមផ្តន្ទាទោសពិរុទ្ធភាពស្ថាពរក៏ដោយ *"ក៏អត្ថន័យរបស់វាពាក់ព័ន្ធនឹងបរិបទនៅដំណាក់កាលមុនសវនាការនៅ អ.វ.ត.ក ដែរ"*[៣៩]។ នៅក្នុងបញ្ហានោះ ម្ចាស់បណ្តឹងឧទ្ធរណ៍បានប្តឹងឧទ្ធរណ៍យ៉ាងជោគជ័យប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស ដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយសំអាងថា ស.ច.ស មិនបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ នៅក្នុងដីកាសម្រេចបដិសេធរបស់ខ្លួនទេ[៤០]។

៦៣. ដោយសារថា សិទ្ធិទទួលការសម្រេចដោយមានសំអាងហេតុត្រឹមត្រូវជាគោលការណ៍សារវ័ន្តនៃច្បាប់នោះ សេចក្តីសម្រេចមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវធានាថាជាសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវដែរ។ ការខកខានមិនបានផ្តល់នូវសំអាងហេតុ

---

ឆ្នាំ ២០០៦ សំណុំរឿងលេខ IT-02-60/1-A កថាខណ្ឌ៩៦; រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកដទៃទៀត សាលដីកា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ សំណុំរឿងលេខ IT-96-23&23/1-A កថាខណ្ឌ៤១)។ នៅក្នុងកថាខណ្ឌ១១ នៃ "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចដោះលែង Nebojsa Pavkovic បណ្តោះអាសន្ន" របស់តុលាការនេះ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinovic និងអ្នកដទៃទៀត (សំណុំរឿងលេខ IT-05-87-AR65.1) អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា "ជាកម្រិតអប្បបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់សំអាងហេតុ ដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួន ទាក់ទិននឹងការសន្និដ្ឋានជាសារវ័ន្តទាក់ទិននឹងសេចក្តីសម្រេចរបស់ខ្លួន"។ សូមមើលផងដែរ៖ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga សំណុំរឿងលេខ ICC-01/04-01/06-774 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I "សេចក្តីសម្រេចលើកទីពីរលើសំណើសុំរបស់រដ្ឋអាជ្ញា និងសំណើសុំដែលបានកែសម្រួលសម្រាប់កាត់បន្ថយតាមវិធាន៨១" ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ៣០៖ "សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវគឺជាធាតុផ្សំមួយនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយថា មានតែសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវទេទើបធ្វើឱ្យការពិនិត្យពិចារណាទៅលើបណ្តឹងឧទ្ធរណ៍អាចប្រព្រឹត្តទៅបាន"។

[៣៨] *ដូចដើងទំព័រខាងលើ* ត្រង់កថាខណ្ឌ២៨។

[៣៩] *ដូចដើងទំព័រខាងលើ* ។

[៤០] *ដូចដើងទំព័រខាងលើ* ត្រង់កថាខណ្ឌ៣០ (សូមមើល កថាខណ្ឌ៣១ អ.ប.ជ បានកត់សម្គាល់ថា កំហុសឆ្គងលើអង្គច្បាប់របស់ ស.ច.ស នឹងតម្រូវឱ្យ អ.ប.ជ ច្រានចោលដីកាសម្រេចរបស់ ស.ច.ស តែមានសំអាងហេតុចាំបាច់ដទៃទៀតដែលត្រូវតម្កល់ដីកាសម្រេចនេះ)។

ពិស្តារ ក្នុងការច្រានចោលនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺជាការបន្ទច់បង្អាក់សិទ្ធិជាសារវ័ន្តនេះ។

៦៤. ដោយការផ្ដល់សិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធពាក្យសុំនោះ អ.វ.ត.ក បានទទួលស្គាល់នូវសារៈសំខាន់នៃសិទ្ធិតាមនីតិវិធីនេះ។ ក្នុងការអនុវត្តជាក់ស្ដែង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវគេបដិសេធចោលមិនអាចដាក់ពាក្យសុំថ្មីដែលកែសម្រួលទេ ដោយសារវិធានផ្ទៃក្នុងបានកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ពាក្យសុំ រយៈពេល ១៥ ថ្ងៃ បន្ទាប់ពីប្រកាសបញ្ចប់កិច្ចស៊ើបសួរ[៤១]។ ពេលនោះមធ្យោបាយដែលនៅសេសសល់សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺប្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។ ហេតុនេះ ដីកាសម្រេចនេះគួរតែមានលក្ខណៈពិស្តារគ្រប់គ្រាន់ ដើម្បីធ្វើឱ្យបណ្ដឹងឧទ្ធរណ៍ដែលជាមធ្យោបាយចុងក្រោយនេះមានន័យពេញលេញ។

៦៥. សម្រាប់សំអាងហេតុទាំងនេះ ការខកខានមិនបានចេញសេចក្ដីសម្រេចដោយមានសំអាងហេតុត្រឹមត្រូវគឺជាការរំលោភបំពានលើគោលការណ៍៤ នៃ *សេចក្ដីប្រកាសស្ដីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការបំពានអំណាច* ដែលបានចែងថា ជនរងគ្រោះគួរតែទទួលបានការអាណិតអាសូរ និងការគោរពដល់សេចក្ដីថ្លៃថ្នូររបស់ខ្លួន[៤២]។ ការបដិសេធចោលដោយគ្មានមូលដ្ឋានដែលមានសំអាងហេតុត្រឹមត្រូវ គឺមិនត្រឹមតែជាការដកហូតនូវសិទ្ធិក្នុងនីតិវិធីជាសារវ័ន្តទេ តែវាក៏ជាការប្រមាថដល់សេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះដែរ ហើយបានធ្វើឱ្យអ្នកទាំងនេះក្លាយជាជនរងគ្រោះម្ដងទៀត ដែលលើកនេះធ្វើឡើងដោយស្ថាប័នតុលាការដែលមានលក្ខណៈអន្តរជាតិតែម្ដង។

៦៦. ក្នុងការខកខានមិនបានផ្ដល់នូវសំអាងហេតុពិស្តារគ្រប់គ្រាន់ ស.ច.ស បានខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមវិធាន២១ "ដើម្បីធានានូវសច្ចភាពផ្លូវច្បាប់ និងតម្លាភាព"។ ស.ច.ស ក៏បានរំលោភបំពានផងដែរទៅលើវិធាន២១(គ) ដោយខកខានមិនបានផ្ដល់ព័ត៌មានឱ្យបានត្រឹមត្រូវដល់ជនរងគ្រោះពីមូលដ្ឋាននៃសេចក្ដីសម្រេចរបស់ខ្លួន បានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់

[៤១] វិធាន២៣*ស្ទួន*(២)។

[៤២] *សេចក្ដីប្រកាសស្ដីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការបំពានអំណាច* អនុម័តដោយសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 40/34 ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ គោលការណ៍ ៤។

ជនរងគ្រោះ ហេតុនេះ ស.ច.ស ខកខានមិនបានគោរពដល់សិទ្ធិរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីទាំងមូល។

***អាស្រ័យហេតុនេះ ...***

៦៧. ហេតុនេះ ទាក់ទិននឹងការខកខានខាងលើរបស់ ស.ច.ស ដីកាសម្រេចបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹង [redacted] គួរត្រូវបានច្រានចោល ហើយសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សម្រាប់សំណុំរឿង០០៣ ប្រឆាំង [redacted] គួរត្រូវបានទទួលយក។

## III. សេចក្តីសន្និដ្ឋាន និង សំណូមពរ

៦៨. ជាសរុបមក ព្យសនកម្មតាមផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍***ពិតជា***ពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតក្នុងកិច្ចស៊ើបសួរ ដែលមានទំនាក់ទំនងដោយផ្ទាល់រវាងស្ថានភាពអង្គហេតុ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរង ដោយសារបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយជនត្រូវចោទ ទោះបី ស.ច.ស ខកខានមិនបានបើកកិច្ចស៊ើបសួរ និងផ្តល់ព័ត៌មានក៏ដោយ។ បន្ថែមលើការអនុវត្តមិនបានត្រឹមត្រូវ និងការបកស្រាយមិនបានត្រឹមត្រូវរបស់ខ្លួន ស.ច.ស មិនមានភាពស្មោះត្រង់ទេ នៅពេលដែលហៅការកំណត់ [redacted] របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា "គ្មានមូលដ្ឋាន" និង "ជាការប៉ាន់ស្មាន" នោះ។ ពួកគាត់ប្រាកដជាជឿជាក់ថា ពួកគាត់អាចលាក់បំពួនយ៉ាងមានសុវត្ថិភាព និងជាអចិន្ត្រៃយ៍បានក្រោមពាក្យថា "សម្ងាត់" ដែលមិនអាចចោទសួរ ឬតវ៉ាបាន។

៦៩. ម្ចាស់បណ្តឹងឧទ្ធរណ៍សូមស្នើដោយគោរពថា អ.ប.ជ គួរ៖

(i) ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះទទួលយកបាន និង

(ii) ច្រានចោលសេចក្តីសម្រេចនៅក្នុងដីកាសម្រេចរបស់ ស.ច.ស ដែលប្រកាសមិនទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានថា៖

ក. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានទទួលព័ត៌មានទាន់ពេលវេលា និងគ្រប់គ្រាន់ស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរសម្រាប់សំណុំរឿង០០៣ និង០០៤ តាមគោលការណ៍សារវ័ន្តនៃភាពយុត្តិធម៌នៅក្នុងនីតិវិធីឡើយ។

ខ. ស.ច.ស ខកខានមិនបានបើកកិច្ចស៊ើបសួរទៅដល់ទីកន្លែង នូវទីតាំងឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍នានានៃបទឧក្រិដ្ឋក្នុងសំណុំរឿង០០៣ និង០០៤ ជាពិសេសដោយសារ វាពាក់ព័ន្ធនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ពោលគឺនៅក្រុងភ្នំពេញ និងភូមិភាគបូព៌ា ហើយ ប្រការដែលពាក់ព័ន្ធផងដែរគឺថា ស.ច.ស ខកខានមិនបានរក្សាឯករាជ្យភាពរបស់ តុលាការ និង

គ. ស.ច.ស អនុវត្តមិនបានត្រឹមត្រូវ និងបកស្រាយមិនបានត្រឹមត្រូវទាំងអង្គហេតុ និង អង្គច្បាប់ ឧទាហរណ៍ "សហឧក្រិដ្ឋកម្មរួម" និង ការរៀបចំ និងគោលបំណងរួម" និង

ឃ. ស.ច.ស ខកខានមិនបានផ្តល់សេចក្តីសម្រេចក្នុងការមិនទទួលយកពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងករណី [redacted] និង

(iii) ពិចារណាទៅលើភាពជាតំណាង និងសារណាតាមផ្លូវច្បាប់ដែលបានដាក់ និង

(iv) ផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ម្ចាស់បណ្តឹងឧទ្ធរណ៍។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ហត្ថលេខា

**សេង ចាន់ធារី**

ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី/ម្ចាស់បណ្តឹងឧទ្ធរណ៍